ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**Kingdom of Cambodia**
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
លេខ ៨៩៣ ឧរម. ធរ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ២០០៥

# ប្រកាស
## ស្តីពី ការបង្កើតក្រុមមន្ត្រីមានសមត្ថកិច្ចចុះត្រួតពិនិត្យ ការអនុវត្តន៍ច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ

888888888888

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស /រកត.នស /០៧០៤ /១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស /រកម /០១៩៦ /០៥ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញច្បាប់ ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស /រកម /០៧០១ /០៩ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០១
- បានឃើញអនុក្រឹត្យលេខ ៣៥អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ពិនិត្យសំណូមពរការងារចាំបាច់របស់ក្រសួង

### សំរេច

**ប្រការ ១:**

បង្កើតក្រុមមន្ត្រីមានសមត្ថកិច្ច នៃអគ្គនាយកដ្ឋានធនធានរ៉ែ ឱ្យចុះបំពេញបេសកកម្មនៅតាមបណ្តាខេត្ត-ក្រុង នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីត្រួតពិនិត្យអំពីប្រសិទ្ធភាពនៃការអនុវត្តន៍ច្បាប់ ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ ។

**ប្រការ ២:**

សមាសភាពក្រុមមន្ត្រីមានសមត្ថកិច្ច មានកំណត់ដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១. | លោក ជូរ ជេតទីវ័ន្ត | អគ្គនាយករងនៃអគ្គនាយកដ្ឋានធនធានរ៉ែ | ប្រធាន |
| ២. | លោក នួន ចាណាន | អនុប្រធាននាយកដ្ឋានធនធានរ៉ែ | សមាជិក |
| ៣. | លោក ហ៊ីង សារឿន | អនុប្រធានការិយាល័យរ៉ែអលោហៈ | សមាជិក |
| ៤. | លោក សោម ស៊ីវណ្ណា | អនុប្រធានការិយាល័យអភិវឌ្ឍន៍ធនធានរ៉ែ | សមាជិក |

៤៥ មហាវិថីព្រះនរោត្តម ខ័ណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥) ២៣.២១១១៤១ , ទូរសារ : ៨៥៥.២៣.៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855.23.211141 , Fax : 855.23.428263

៥. លោក ប៊ិន ថេត មន្ត្រីនាយកដ្ឋានភូគព្ភសាស្ត្រ សមាជិក

**ប្រការ ៣:**

ក្នុងការចុះបំពេញបេសកកម្ម មន្ត្រីមានសមត្ថកិច្ចទាំងអស់ត្រូវស្លៀកពាក់ជាឯកសណ្ឋានមន្ត្រីធនធានរ៉ែនៃអគ្គនាយកដ្ឋានធនធានរ៉ែ និងមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្ត-ក្រុង និងត្រូវមានលិខិតបញ្ជាបេសកកម្មរបស់ក្រសួង ។

**ប្រការ ៤:**

ក្រុមមន្ត្រីមានសមត្ថកិច្ច មានបេសកកម្មដូចតទៅ ៖

- ពិនិត្យនិងណែនាំអំពីការងារជំនាញ និងបច្ចេកទេស ស្តីពីរបៀបរបបគ្រប់គ្រងលើរាល់ប្រតិបត្តិការធនធានរ៉ែ សំដៅលើកកំពស់ប្រសិទ្ធភាពទាំងបច្ចេកទេស សេដ្ឋកិច្ច សុវត្ថភាពពលកម្ម និងការការពារបរិស្ថាន ។
- ចុះត្រួតពិនិត្យការអនុវត្តន៍កិច្ចព្រមព្រៀង រួមទាំងការបំពេញកាតព្វកិច្ចហិរញ្ញវត្ថុ និងកាតព្វកិច្ចផ្សេងៗទៀតរបស់ក្រុមហ៊ុន អាជីវករ ឬ សម្បទានិក ដែលបាននិងកំពុងធ្វើប្រតិបត្តិការធនធានរ៉ែនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។
- ជំរុញសកម្មភាពទារបំណុល ចំពោះក្រុមហ៊ុន អាជីវករ ឬសម្បទានិកទាំងឡាយណាដែលខកខានពុំបានបំពេញកាតព្វកិច្ចហិរញ្ញវត្ថុ ក្នុងកិច្ចប្រតិបត្តិការធនធានរ៉ែ ។ ក្នុងករណីនៅតែមិនព្រមទូទាត់សំណងនឹងត្រូវចាត់វិធានការតឹងទារតាមផ្លូវច្បាប់ ។
- ដោះស្រាយរាល់វិវាទក្នុងកិច្ចប្រតិបត្តិការធនធានរ៉ែ ដែលអាចកើតមានឡើងជាយថាហេតុ ។
- លើកឡើងនូវវិធានការផ្សេងៗ គិតរួមទាំងវិធានការរដ្ឋបាលនិងបច្ចេកទេស ការផាកពិន័យ ដើម្បីដាក់ជូនក្រសួងពិនិត្យនិងសំរេច ដោយអនុលោមទៅតាមច្បាប់ ពិសេសជំពូកទី៨ ស្តីពីទោសប្បញ្ញត្តិនៃច្បាប់ស្តីពីការគ្រប់គងនិងការធ្វើអាជីវកម្មធនធានរ៉ែ ដើម្បីទប់ស្កាត់ និងបង្ក្រាបចំពោះរាល់ទង្វើខុសច្បាប់ និងមិនប្រក្រតីនានា នៅក្នុងកិច្ចដំណើរការនិងការគ្រប់គ្រងប្រតិបត្តិការធនធានរ៉ែ ។
- ប្រមូលទិន្នន័យ និងរៀបចំរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆ្នាំអំពីលទ្ធផលនៃបេសកកម្មរបស់ក្រុមការងារ ជូនរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលពិនិត្យ និងផ្តល់ការណែនាំ ។

**ប្រការ ៥:**

ប្រកាសនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ស៊ុយ សែម

**ចម្លងជូន :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- គ្រប់សាលាខេត្ត-ក្រុង
- គ្រប់មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្ត-ក្រុង
- ដូចប្រការ ២ "ដើម្បីមុខការ"
- ឯកសារ - កាលប្បវត្តិ